# **បត្តិទានគាថា** ប្រែកាព្យ

## បទព្រហ្មគីតិ

| | |
|---|---|
| *កម្មជាកុសលឯណា* | *ដែលជាការឥតសៅហ្មង* |
| *យើងខ្ញុំបានកសាង* | *ដោយកាយវាចាចិត្តពិត ។* |
| *កុសលទាំងអស់នោះ* | *អាចជួយដោះជួយបង្អិត* |
| *នាំសត្វឱ្យជាប់ចិត្ត* | *ស្ថិតនៅនាស្ថានឧត្តម ។* |
| *សត្វណាមានសញ្ញា* | *គឺទេព្តាមនុស្សឬព្រហ្ម* |
| *ដែលមានស័ក្តិតូចធំ* | *ព្រមទាំងសត្វឥតសញ្ញា ។* |
| *សូមបានចំណែកបុណ្យ* | *ដែលជាគុណល្អថ្លៃថ្លា* |
| *យើងខ្ញុំបានរចនា* | *ចាត់ចែងការកុសលនឹង ។* |
| *ម្យ៉ាងទៀតសត្វឯណា* | *ឆ្ងាយអស្ចារ្យពុំបានដឹង* |
| *សូមទេព្តាទៅប្តឹង* | *ឱ្យដំណឹងយ៉ាងនេះថា ។* |
| *នរជនឈ្មោះឯណោះ* | *ស្រីឬប្រុសបានជ្រះថ្លា* |
| *កសាងបុញ្ញកិរិយា* | *វត្ថុជាល្អឆើតឆាយ ។* |
| *ហើយគេឧទ្ទិសផល* | *ឱ្យបានដល់អ្នកទាំងឡាយ* |
| *សូមមានចិត្តស្រស់ស្រាយ* | *បន្ទន់កាយទទួលយក ។* |
| *សត្វក្នុងលោកទាំងអស់* | *ដែលនៅរស់តរៀងមក* |
| *ដោយបានបរិភោគ* | *នូវអាហារទើបរស់បាន ។* |
| *សត្វទាំងអស់នោះណា* | *សូមសុខាសព្វគ្រប់ប្រាណ* |
| *អាហារយ៉ាងចំណាន* | *សូមឱ្យបានកុំខានហោង ៕* |

វត្តធម្មារាម

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៉ាន់ អ៊ុង** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣

វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១២

